ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ

# កំណត់ហេតុ

## កិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្ដាហ៍
## ថ្ងៃចន្ទ ទី១២ ខែសីហា ឆ្នាំ២០១៩ នៅសាលប្រជុំ អ.ជ.ប.ជ.អ

### ១. សេចក្ដីផ្ដើម

នៅវេលាម៉ោង ៩:០០ នាទីព្រឹកថ្ងៃចន្ទ ទី១២ ខែសីហា ឆ្នាំ២០១៩ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្ដាហ៍ ក្រោមការដឹកនាំកិច្ចប្រជុំដោយឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយមានការចូលរួមពីអគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋាន វត្តមាន ១៣នាក់ បេសកកម្ម ០០នាក់ អវត្តមានចំនួន ០២នាក់ ច្បាប់ ០១នាក់ ។

### ២. ប្រធានបទនៃកិច្ចប្រជុំ

- រាយការណ៍លទ្ធផលការងារសប្ដាហ៍កន្លងមក និងការងារសប្ដាហ៍បន្ទាប់តាមនាយកដ្ឋាននីមួយៗ
- បូកសរុប និងណែនាំរបស់ឯកឧត្តមអគ្គលេខាធិការ

### ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

៣.១. នាយកដ្ឋានចលនាប្រភពធនធាន (CRM) ៖

ក. សកម្មភាពបានអនុវត្ត

- បានរៀបចំគម្រោងចុះ Monitoring ខែសីហា ឆ្នាំ២០១៩ ។
- បានរៀបចំរបាយការណ៍ សម្រាប់សិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី២៦ ខែ០៧ ឆ្នាំ២០១៩ ។
- បានចូលរួមនិងរៀបចំកំរងសំនួរ សិក្សាស្រាវជ្រាវនិងប្រមូលព័ត៌មានពីស្ថានភាពនៃការផ្ដល់សេវាបង្ការ ថែទាំ និងព្យាបាលអ្នកជំងឺអេដស៍ នៅមន្ទីរពេទ្យបង្អែកពោធិចិនតុង ។

ខ. សកម្មភាពសប្តាហ៍បន្ទាប់

- បន្តរៀបចំប្រមូលព័ត៌មានស្តីពីស្ថានភាពទូទៅនៃការផ្តល់សេវាព្យាបាលអ្នកជំងឺអេដស៍ ខេត្តត្បូងឃ្មុំ កំពង់ចាម និងស្វាយរៀង ។
- បន្តរៀបចំសេចក្តីព្រាង របៀបវារៈសម្រាប់កម្មវិធីកិច្ចប្រជុំពេញអង្គលើកទី២ សន្និបាតបុណ្យអុំទូកទិវាអេដស៍១ធ្នូ ( រង់ចាំប្រធានបទដែលនឹងទទួលការឯកភាពពីឯកឧត្តមទេសរដ្ឋមន្ត្រី )។

៣.២. នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ (PMER) ៖

ក. សកម្មភាពបានអនុវត្ត

- បានចងក្រងរបាយការណ៍សកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែកក្កដា ឆ្នាំ២០១៩។
- បានរៀបចំរបាយការណ៍វឌ្ឍនភាពទូលំទូលាយ និង ពហុវិស័យឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ សម្រាប់ឆមាសទី១ ឆ្នាំ២០១៩។
- ពិនិត្យមើលរបាយកាណ៍ស្តីពីការប៉ាន់ប្រមាណថ្នាក់ជាតិការចំណាយប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៦ និង២០១៧។
- ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៩ ចុះសិក្សាស្វែងយល់ពីសេវាថែទាំ និងព្យាបាលអ្នកផ្ទុកមេរោគអេដស៍ នៅមន្ទីរពេទ្យព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹម។
- ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩ រៀបចំកិច្ចប្រជុំក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (ឆ្នាំ២០១៩-២០២៣) នៅ អ.ជ.ប.ជ.អ ដើម្បីពិនិត្យកែសម្រួលសេចក្តីព្រាងលើកទី៤ នឹងគ្រោងប្រជុំក្រុមការងារនៅថ្ងៃទី២៣ សីហា ឆ្នាំ២០១៩ និងស្នើសុំបង្ហាញក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ដើម្បីបង្ហាញនិងពិភាក្សាពីសកម្មភាពពាក់ព័ន្ធជាមួយក្រសួងស្ថាប័ននានា។
- ពិនិត្យមើលរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាសន្ទស្សន៍នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ (Stigma Index 2.0) និងរៀបចំឯកសារសម្រាប់សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៩។
- ពិនិត្យកែសម្រួលនិយាមបែបបទសម្រាប់អ្នកផ្តល់សេវាក្នុងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ សម្រាប់ប្រជាជនទូទៅ និងក្រុមប្រឈមខ្ពស់ក្នុងខេត្តបាត់ដំបង។
- បានបញ្ចប់ការរៀបចំលិខិតស្នើសុំរបាយការណ៍វឌ្ឍនភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ឆមាសទី២ ឆ្នាំ២០១៩។

ខ. សកម្មភាពសប្តាហ៍បន្ទាប់

- បន្តចងក្រងរបាយការណ៍វឌ្ឍនភាពការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ទូលំទូលាយ និងពហុវិស័យ សម្រាប់ឆមាសទី១ ឆ្នាំ២០១៩។
- បន្តការកែសម្រួលសេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (ឆ្នាំ២០១៩-២០២៣) រៀបចំកិច្ចប្រជុំនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាសន្ទស្សន៍នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ ឆ្នាំ២០១៩ (Stigma Index 2:0, 2019) ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ នៅសណ្ឋាគារភ្នំពេញ។
- បន្តការកែសម្រួលបញ្ចប់របាយការណ៍ស្តីពីលទ្ធផលនៃការប៉ាន់ប្រមាណការចំណាយថ្នាក់ជាតិស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦(NASA VI) ដែលនឹងត្រូវបញ្ចប់ក្នុងខែសីហា ឆ្នាំ២០១៩។
- ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ពិនិត្យកែសម្រួលបញ្ចប់និយាមបែបបទសម្រាប់អ្នកផ្តល់សេវាក្នុងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ សម្រាប់ប្រជាជនទូទៅនិងក្រុមប្រឈមខ្ពស់ក្នុងខេត្តបាត់ដំបង។

៣.៣. នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ (PCS) ៖

ក. សកម្មភាពបានអនុវត្ត

- បានរៀបចំការងារបច្ចេកទេសសម្រាប់កិច្ចប្រជុំត្រីមាស EE/MCPI ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ដែលមានខេត្តចំនួន៤ គឺ ភ្នំពេញ កំពង់ចាម បន្ទាយមានជ័យ ក្រុងព្រះសីហនុ។
- បានរៀបចំការងារបច្ចេកទេសសម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោល EE/MCPI នៅខេត្តកំពត ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩ ។
- មន្ត្រីបានចុះប្រមូលព័ត៌មាន នៅឈូក ស ។

ខ. សកម្មភាពសប្តាហ៍បន្ទាប់

- បន្តរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីបរិយាកាស គាំទ្រច្បាប់ គោលនយោបាយ និងភារៈកិច្ចក្នុងការគាំទ្រការឆ្លើយតបចំពោះមេរោគអេដស៍ថ្នាក់ខេត្ត (សៀមរាប) ថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩។
- បន្តរៀបចំកិច្ចប្រជុំប្រចាំត្រីមាសស្តីពីការបង្កបរិយាកាសអំណោយផល សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់ ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ។
- បន្តរៀបចំ ការងារបច្ចេកទេស សម្រាប់ចុះអភិបាលកិច្ចលើការងារការបង្កបរិយាកាសគាំទ្រច្បាប់ និងគោលនយោបាយ ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ខេត្ត ។

៣.៤. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (A/F) ៖

ក. សកម្មភាពបានអនុវត្ត

ការងាររដ្ឋបាល

- បានប្រជុំដើម្បីតាមដាន និងដោះស្រាយការងារក្នុងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ សម្រាប់សប្តាហ៍ទី៥ខែកក្កដា នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៩ ពីម៉ោង៣៖៣០ ដល់៤៖៣០រសៀល ដើម្បីពិភាក្សាពី ផែនការសកម្មភាពការងារដែលគ្រោងនឹងអនុវត្តនៅក្នុងសប្តាហ៍។ ជាមួយគ្នានោះមានការកំណត់វេនប្រចាំការរបស់មន្ត្រីនៅកន្លែងទទួលភ្ញៀវ ការសម្អាតអគារ ការរក្សាអនាម័យនៅបន្ទប់ទឹក ការត្រួតពិនិត្យថែទាំយានយន្ត និងការពង្រឹងវិន័យអ្នកបើកបរ សន្តិសុខ និងការរក្សាសណ្តាប់ធ្នាប់ត្រូវបានពិភាក្សា និងអនុវត្តបានទៅតាមការណែនាំ។
- បានអមដំណើរឯកឧត្តមទេសរដ្ឋមន្ត្រី ក្នុងការធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីដំណើរការរបស់គ្លីនិកឈូកស និងមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹមក្នុងការផ្តល់សេវាដល់អ្នកជំងឺអេដស៍ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង០៨:៣០ ដល់ម៉ោង១១៖៤៥ព្រឹក។ ការចុះសិក្សាស្រាវជ្រាវនេះមានការចូលរួមពី តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសុខាភិបាល អង្គការKHANA អង្គការHP+ អង្គការMHC អង្គការCWPD និងថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ផងដែរ។
- បានចាត់បញ្ជូនមន្ត្រី ទៅចូលរួមទទួល គណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយ ឯ.ឧ. ម៉ៃទ្រីប៉ាឡាស៊ីរីសេនា ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យសង្គមនិយមស្រីលង្កា និងលោកជំទាវ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវ រដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៨ សីហា ២០១៩ វេលាម៉ោង០៩:១៥ព្រឹក នៅមុខព្រះបរមរាជវាំង។
- បានទាក់ទងជាមួយខេត្តស្វាយរៀង ត្បូងឃ្មុំ និងកំពង់ចាម អំពីការរៀបចំសិក្ខាសាលាគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ឆមាសទី២ ឆ្នាំ២០១៩ ដែលនឹងប្រព្រឹត្ត ទៅពីថ្ងៃទី១៣ដល់១៥ ខែសីហា ឆ្នាំ២០១៩។ កម្មវិធីសិក្ខាសាលាខេត្តស្វាយរៀងនៅថ្ងៃទី១៣ សីហា វេលាម៉ោង២៖៣០រសៀលនោះ នឹងរៀបចំនៅមន្ទីរសុខាភិបាល ដោយមានការចូលរួមពីអភិបាលរងខេត្ត តូច ប៉ូលីវ៉ា និងសមាជិក៥០នាក់។ ចំណែកឯកម្មវិធីនៅខេត្តត្បូងឃ្មុំ អភិបាលរងខេត្ត និងសមាជិក៣១នាក់ និងខេត្តកំពង់ចាម អភិបាលខេត្ត និងសមាជិក ៣៥នាក់នឹងចូលរួមសិក្ខាសាលា។
- បានរៀបចំលិខិតចាត់តាំងលោកជំទាវ ខាន់ ចាន់មុនី អគ្គលេខាធិការរង ចូលរួមការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល សម្រាប់រយៈពេល១២០ម៉ោង ជំនួសលោកជំទាវ ស៊ឹម ខេងខាំ ដែលត្រូវបានស្នើសុំប្តូរដោយហេតុបានចូលរួមការបណ្តុះបណ្តាលកាលពីលើកមុនរួចហើយ។

ការងារបុគ្គលិក

- បានបញ្ចប់ការសរសេរព្រឹត្តប័ត្រពិន្ទុ ស្នើដំឡើងកាំប្រាក់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ៣១នាក់សម្រាប់ឆ្នាំ២០២០។

- បានរៀបចំលិខិតបង្គាប់ការ បង្កើតគណៈកម្មការត្រួតពិនិត្យ វាយតម្លៃ និងដាក់ពិន្ទុស្នើសុំដំឡើងថ្នាក់ ជូនថ្នាក់ដឹកនាំ និង មន្ត្រីរាជការសម្រាប់ឆ្នាំ២០២០។
- បានតាមដានអំពីការបញ្ចូលប្រាក់រំឭកឡើងតាមវេនជូនថ្នាក់ដឹកនាំ មន្ត្រីរាជការចំនួន១២រូប។
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមាន ឯកឧត្តម ឈឹម ឃិនដារ៉េត ជាវាគ្មិន នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ និងមានការចូលរួមពីថ្នាក់ ដឹកនាំ និងមន្ត្រីនៅខុទ្ទកាល័យ និងអគ្គលេខាធិការដ្ឋាន។

**ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

- បានទទួលសៀវភៅវិស័យអេដស៍ចំនួន៣.៥០០ក្បាលបញ្ចូលឃ្លាំង នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩។
- បានទូទាត់ឯកសារចំណាយរដ្ឋទេយ្យបុរេប្រទានចំនួន២គឺ ៖
  - ចំណាយផ្សេងៗ ចំនួន១
  - បេសកកម្មក្រៅប្រទេស ចំនួន១
- បន្តតាមដានឯកសារចំនួន៧ នៅក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ឯកសារ២នៅរតនាគារជាតិមាន៖
  - ទូទាត់រដ្ឋទេយ្យបេសកកម្មក្រៅប្រទេសចំនួន៤
  - ទូទាត់រដ្ឋទេយ្យបុរេប្រទានចំណាយផ្សេងៗចំនួន២
  - ឯកសារបង់ពន្ធរថយន្តចំនួន១
  - គោលការណ៍ជានាចំណាយយុទ្ធនាការក្នុងពិធីបុណ្យអុំទូក
  - គោលការណ៍ជានាចំណាយទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ
- អគ្គាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងមកធ្វើអធិការកិច្ចលើការគ្រប់គ្រងចំណូលចំណាយនៅ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅចន្លោះថ្ងៃទី២៣ ខែកញ្ញា និង១១ ខែតុលា ឆ្នាំ២០១៩ ខាងមុខនេះ។

**ខ. សកម្មភាពសប្តាហ៍បន្ទាប់**

- ប្រជុំតាមដាន និងដោះស្រាយការងារនៅក្នុងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ សប្តាហ៍ទី២ ខែសីហា នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ម៉ោង ៣៖៣០ ដល់៤៖៣០រសៀល។
- រៀបចំការប្រជុំគណៈកម្មការត្រួតពិនិត្យ វាយតម្លៃ និងដាក់ពិន្ទុស្នើសុំដំឡើងថ្នាក់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ ។
- បញ្ចប់របៀបវារៈ និងឯកសារស្នើសុំរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ដែលរៀបចំដោយ នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ ចាប់ពីម៉ោង ០៩ ព្រឹក។

- ត្រៀមដើម្បីចូលរួមការពារផែនការថវិកា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅកម្រិតនយោបាយ ក្នុងខែសីហា ឆ្នាំ២០១៩។
- រៀបចំលិខិតស្នើសុំទីតាំងរៀបចំកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតទៅទីស្តីការគណៈរដ្ឋមន្ត្រី។
- រៀបចំលិខិតស្នើសុំទីតាំងប្រគំតន្ត្រី នៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងទិវាប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៩។

## ៤. ការបូកសរុប និងមតិណែនាំរបស់ ឯកឧត្តម អគ្គលេខាធិការ

ឯកឧត្តមប្រធានអង្គប្រជុំបានធ្វើការបូកសរុប ផ្តល់មតិណែនាំមួយចំនួនដូចខាងក្រោម៖

- នាយកដ្ឋាន CRM ត្រូវមានពត៌មានអោយបានច្បាស់លាស់ដែលទាក់ទងនឹងស្ថានភាពខេត្តនីមួយៗ និងចំនួនអ្នកផ្ទុកមេរោគអេដស៍។
- នាយកដ្ឋាន CRM ពង្រឹងការងារដាក់ស្តែងនៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងទិវាប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៩ ។
- នាយកដ្ឋាន PMER ត្រូវពង្រឹងការងាររដ្ឋបាល ។
- នាយកដ្ឋាន PMER ត្រូវប្រមូលពត៌មានវិទ្យាសាស្ត្រទាក់ទងនឹងស្ថានភាពមេរោគអេដស៍ ជំងឺអេដស៍សម្រាប់ការចែករំលែកដល់បុគ្គលិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- នាយកដ្ឋាន PCS រាល់ការចុះបង្រៀនតាមខេត្ត ឬវគ្គបណ្តុះបណ្តាល ត្រូវមានកំនត់ត្រារាល់សំនួរដែលគេសួរ ដើម្បីស្វែងរកចម្លើយដែលត្រឹមត្រូវសម្រាប់វគ្គបណ្តុះបណ្តាលលើកក្រោយៗទៀត។
- គ្រប់នាយកដ្ឋានទាំងអស់ត្រូវយក ស.ជ.ណ លេខ២១៣ មកពិនិត្យឡើងវិញអំពីទិសដៅភារកិច្ច របស់នាយកដ្ឋាននីមួយៗ ដើម្បីក្តាប់ពត៌មានអោយបានជាក់លាក់ពីវឌ្ឍនភាព ។/.

ថ្ងៃចន្ទ ១២កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១៩

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | អ្នកធ្វើកំណត់ហេតុ |
|---|---|---|
| **អគ្គលេខាធិការ** | ប្រធាននាយកដ្ឋានផែនការ គ្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ | |
| ឯកឧត្តមវេជ្ជ. តែង គន្ធី | លោកវេជ្ជ. ទេព ណាវុធ | វេជ្ជ. ព្រាប សុជាតា |